# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០៦០/២៤.......ន. គ. ស .......

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា គ.ស.២០២៤

## សេចក្តីបំភ្លឺ

ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ **និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសង្កេតឃើញថា មានបណ្តាញព័ត៌មាននិងបណ្តាញសង្គមមួយចំនួន ពិសេស វិទ្យុបារាំងអន្តរជាតិ (RFI) តាមរយៈគេហទំព័រ បានចុះផ្សាយនិងផ្សព្វផ្សាយពាក់ព័ន្ធអំពីការតម្រូវឱ្យ **សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ** បង់ពន្ធជាទឹកប្រាក់ចំនួន ១៨ ៨០០ ០០០ (ដប់ប្រាំបីលានប្រាំបីសែន)រៀល ដែលការណ៍នេះអាចឱ្យសមាគមគ្រូបង្រៀនកម្ពុជា-ឯករាជ្យ ប្រឈមនឹងការបិទទ្វារ ដោយសមាគមពុំមានលទ្ធភាពបង់។ ការផ្សព្វផ្សាយនេះ គឺជាការមិនពិតនិងពុំបានឆ្លុះបញ្ចាំងពីការអនុវត្តរបស់អគ្គនាយកដ្ឋានពន្ធដារនោះទេ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារ បានចេញលិខិតបំភ្លឺជាសាធារណៈ និងស្នើឱ្យសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និងវិទ្យុបារាំងអន្តរជាតិ (RFI) កែតម្រូវខ្លឹមសារ នៃការផ្សាយរបស់ខ្លួនឡើងវិញ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤។ ឆ្លើយតបនឹងសេចក្តីបំភ្លឺនេះ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានចេញសេចក្តីថ្លែងការជាថ្មី នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ ដោយបញ្ជាក់ថាជាសេចក្តីសម្រេចពិន័យអន្តរការណ៍ ប៉ុន្តែមិនបានបញ្ជាក់អំពីអំពើល្មើសនោះឡើយ។

ដូច្នេះ ន.គ.ស. សូមបំភ្លឺជូនសាធារណៈជនមេត្តាជ្រាបថា៖ ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម បានកំណត់កាតព្វកិច្ចជាសារវន្តសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ជាអាទិ៍ (១).ការកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ (២).ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន (៣).ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ តាមលក្ខខណ្ឌកំណត់។ ការបំពានកាតព្វកិច្ចណាមួយ ជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ អនុលោមតាម **អនុក្រឹត្យលេខ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម**។ ដើម្បីជំរុញការអនុវត្តកាតព្វកិច្ចទាំងនេះ និយ័តករបានធ្វើការផ្សព្វផ្សាយនិងបណ្តុះបណ្តាលស្តង់ដា ជូនដល់សហគ្រាស និងអង្គភាពមិនស្វែងប្រាក់ចំណេញ ជាច្រើនលើក ដែលចាប់ពីឆ្នាំ២០១៦ ហូតដល់ពេលនេះ ន.គ.ស. បានធ្វើការផ្សព្វផ្សាយនិងបណ្តុះបណ្តាលចំនួន **១២៦លើក** *ដែលប្រាសចាកពីការលើកឡើងរបស់សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ដែលថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានផ្សព្វផ្សាយអនុក្រឹត្យពិន័យអន្តរការណ៍ឱ្យបានទូលំទូលាយដល់អង្គការ សមាគមឡើយ*។ មិនតែប៉ុណ្ណោះ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ន.គ.ស. បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) និងអង្គការ សមាគមផ្សេងទៀត ក្នុងក្របខណ្ឌនៃការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល។

ចំពោះករណី សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ, នាឆ្នាំ២០២២ ន.គ.ស. បានធ្វើការចុះត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម រួមជាមួយសមាគម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញចំនួន ១០ផ្សេងទៀត ហើយជាលទ្ធផល ន.គ.ស. រកឃើញថា សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និងសមាគមមួយចំនួន មិនបានអនុវត្តកាតព្វកិច្ចដែលកំណត់ដោយច្បាប់ និងបានសម្រេចចេញលិខិតពិន័យអន្តរការណ៍អនុលោមតាម**អនុក្រឹត្យលេខ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម**។

ដូច្នេះ ន.គ.ស. សូមជម្រាបជូនដល់សាធារណៈជន សូមមេត្តាជ្រាបអំពីការសម្រេចនេះ ក្នុងគោលដៅលើកកម្ពស់អនុលោមភាពនិងវប្បធម៌គណនេយ្យ និងកាត់បន្ថយវប្បធម៌និទណ្ឌភាព ដើម្បីការពារឱ្យបានដាច់ខាតនូវ *"នីតិរដ្ឋ"* ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់រាជរដ្ឋាភិបាលកម្ពុជា និងរបស់យើងទាំងអស់គ្នា។ ដើម្បីរួចកាតព្វកិច្ច ន.គ.ស. លើកទឹកចិត្តឱ្យ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ចុះបញ្ជីក្នុង **ប្រព័ន្ធគ្រប់គ្រងការដាក់តម្កល់របាយការណ៍-ហិរញ្ញវត្ថុ** (E-Filing) និងអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដូចសមាគម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដទៃទៀតដែរ។

**និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111